ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

# លក្ខខណ្ឌយោង

## សម្រាប់បុគ្គលិកជាប់កិច្ចសន្យាចំនួន ១រូប

## សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា បានកំណត់យកអាទិភាពគន្លឹះចំនួន ៥ រួមមាន មនុស្ស ផ្លូវ ទឹក ភ្លើង និង បច្ចេកវិទ្យា នៅក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១។ នៅក្នុងអាទិភាព បច្ចេកវិទ្យា គឺផ្តោតជាសំខាន់ក្នុងបច្ចកោណទី ៥ ស្តីអំពី ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល។ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០២៥ រួចហើយផងដែរ ដែលអនុវត្តក្នុង ៣ ដំណាក់កាលគឺ ដំណាក់កាលទី ១ (២០២១-២០២៥)៖ ផ្តោតលើការកសាងមូលដ្ឋានគ្រឹះឌីជីថល និងការចាប់យកឌីជីថល, ដំណាក់កាលទី២ (២០២៦-២០២៣០)៖ ផ្តោតលើការចាប់យកឌីជីថល និងការធ្វើបរិវត្តកម្មឌីជីថល និងដំណាក់កាលទី៣ (២០៣១-២០៣៥)៖ ផ្តោតលើការធ្វើបរិវត្តកម្មឌីជីថល។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការរាជរដ្ឋាភិបាល លើការសម្របសម្រួល និងដឹកនាំការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ផ្អែកតាមក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ដោយមានអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលជាសេនាធិការបច្ចេកទេស។ អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល បង្កើតឡើងក្នុងខែមិថុនា ឆ្នាំ២០២៣ ស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានបេសកកម្មដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលនៃព្រះរាជាណាចក្រកម្ពុជា ដោយឈរលើគោលការណ៍សេដ្ឋកិច្ចទីផ្សារ និងសមធម៌សង្គម អនុលោមតាមគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថល។

ដើម្បីគាំទ្រដល់បេសកកម្មខាងលើ, អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល មានតម្រូវការធនធានមនុស្សជាបុគ្គលិកជាប់កិច្ចសន្យាចំនួន ១រូប ដូចខាងក្រោម៖

- **អ្នកគ្រប់គ្រងម៉ាស៊ីនមេ (System Administrator)** **១រូប**

## ភារកិច្ច និងគុណវុឌ្ឍិ

### អ្នកគ្រប់គ្រងកម្មវិធីម៉ាស៊ីនមេ (Application System Adminstrator) - ១រូប

**ភារកិច្ច**

- សម្របសម្រួល ប្រមូល និងវិភាគលើតម្រូវការរបស់អ្នកប្រើប្រាស់និងស្នើដំណោះស្រាយ
- គាំទ្រ និងត្រួតពិនិត្យជាប្រចាំរាល់មុខងារទាក់ទងនឹងម៉ាស៊ីនមេ និងមូលដ្ឋានទិន្នន័យ (Database) ដូចជាការតាមដាននិងត្រួតពិនិត្យ ការរក្សាទុកនិងទាញត្រលប់មកវិញ ការគ្រប់គ្រងឧប្បត្តិហេតុ
- រៀបចំ និងតំឡើងសូហ្វវែរផ្សេងៗស្របតាមនិម្មាបនកម្មរបស់ប្រព័ន្ធ ឬកម្មវិធី
- ចូលរួមក្នុងការរៀបចំនិម្មាបនកម្ម និងរចនាសម្ព័ន្ធមូលដ្ឋានទិន្នន័យ
- តាមដាន និងត្រួតពិនិត្យជាប្រចាំលើដំណើរការរបស់ម៉ាស៊ីនមេដើម្បីធានាបានលទ្ធផលតាមតម្រូវការ

- ចូលរួមកំណត់ និងរៀបចំស្តង់ដារនៃម៉ាស៊ីនមេដែលប្រើប្រាស់ជាក្របខណ្ឌរួម
- ផ្តួចផ្តើម ជំរុញ និងស្រាវជ្រាវពីនិន្នាការវិវត្តថ្មីៗពាក់ព័ន្ធនឹងដំណើរការនៃការគ្រប់គ្រងម៉ាស៊ីនមេ
- បំពេញការងារផ្សេងទៀតតាមការប្រគល់ជូនពីថ្នាក់ដឹកនាំ។

**គុណវុឌ្ឍិ**

- មានសញ្ញាបត្របរិញ្ញាបត្រវិទ្យាសាស្ត្រកុំព្យូទ័រ, ព័ត៌មានវិទ្យា ឬប្រហាក់ប្រហែល
- មានជំនាញច្បាស់លាស់ និងប្រើប្រាស់ជាប្រចាំលើប្រព័ន្ធប្រតិបត្តិការ Linux, Ubuntu
- មានបទពិសោធន៍យ៉ាងតិច ១ឆ្នាំ ក្នុងការគ្រប់គ្រងកម្មវិធីម៉ាស៊ីនមេ ឬទាក់ទងនឹងផ្នែកសុវត្ថិភាពរបស់ម៉ាស៊ីនមេ និងមូលដ្ឋានទិន្នន័យមានបទពិសោធន៍លើការប្រើប្រាស់កម្មវិធីដូចជា Kubernetes, Docker, S3, Nginx, Apache
- មានចំណេះដឹងបន្ថែមលើការគ្រប់គ្រងមូលដ្ឋានទិន្នន័យ SQL និង NoSQL
- មានចំណេះដឹងបន្ថែមទាក់ទងនឹងផ្នែកសុវត្ថិភាពរបស់ម៉ាស៊ីនមេ និងមូលដ្ឋានទិន្នន័យ
- មានជំនាញច្បាស់លាស់ក្នុងការដោះស្រាយបញ្ហាបច្ចេកទេស និងចាប់យកបានលឿនទៅលើការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ
- មានជំនាញក្នុងការសរសេរឯកសារ និងមានទំនាក់ទំនងការងារល្អ
- អាចបំពេញការងារដោយឯករាជ្យ និងជាក្រុមបានល្អ
- មានអត្តចរិតស្លូតបូត, ស្មោះត្រង់, ឧស្សាហ៍, ព្យាយាម និងគោរពក្រមសីលធម៌វិជ្ជាជីវៈ។

## ការកំណត់ពេលនៃកិច្ចសន្យា

កិច្ចសន្យាត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ១ឆ្នាំម្តង តាមគោលការណ៍កំណត់របស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ថ្នាក់ដឹកនាំគ្រប់គ្រង

បេក្ខភាពដែលបានជ្រើសរើស នឹងត្រូវបំពេញតួនាទី និងភារកិច្ចនៅក្នុងអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយត្រូវរាយការណ៍ជូនថ្នាក់ដឹកនាំតាមឋានានុក្រមចាប់ពីថ្នាក់ការិយាល័យ, ថ្នាក់នាយកដ្ឋាន និងរហូតដល់ថ្នាក់អគ្គនាយក។

## ការរាយការណ៍

បុគ្គលិកជាប់កិច្ចសន្យា ត្រូវបំពេញការាងរឱ្យបានល្អ និងម៉ត់ចត់ តាមតួនាទីដែលខ្លួនទទួលបន្ទុក, ដោយត្រូវរៀបចំរបាយការណ៍លទ្ធផលការងាររបស់ខ្លួនជាប្រចាំខែ និងដាក់ជូនថ្នាក់ដឹកនាំតាមឋានានុក្រមដែលបានកំណត់នៅក្នុងអង្គភាពដែលខ្លួនបំពេញការងារសម្រាប់ភ្ជាប់ការស្នើសុំការបើកផ្តល់ប្រាក់បៀវត្សប្រចាំខែ។

## ទីតាំងបំពេញការងារ

បេក្ខភាពដែលបានជ្រើសរើសត្រូវបំពេញការងារនៅ អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ថិតនៅក្នុងមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច, មហាវិថីអូស៊ីអាយស៊ី, សង្កាត់ជ្រោយចង្វារ, ខណ្ឌជ្រោយចង្វារ, រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

## បរិក្ខារ និងបរិស្ថានការងារ

បរិក្ខារការងារ ដូចជា តុការិយាល័យ កៅអី និងសេវាអ៊ីនធឺណិត នឹងត្រូវផ្តល់ជូនសម្រាប់បំពេញការងារ។ ដោយឡែក បេក្ខជន-បេក្ខនារីអាចប្រើប្រាស់កុំព្យូទ័រយួរដៃ ឬសម្ភារការិយាល័យផ្ទាល់ខ្លួនផ្សេងទៀតតាមការចាំបាច់របស់ខ្លួន សម្រាប់បំពេញការងារ និងសម្រេចលទ្ធផលការងារប៉ុន្តែត្រូវគោរពគោលការណ៍របស់អង្គភាព។ បេក្ខជន-

បេក្ខនារីដែលបានជ្រើសរើសចូលបម្រើការងារមិនត្រូវបានអនុញ្ញាតឱ្យធ្វើការងារ និងទំនាក់ទំនងផ្សេងៗលើការងារផ្ទាល់ខ្លួនក្រៅពីការងារដែលចាត់តាំងដោយអគ្គនាយកដ្ឋានក្នុងកំឡុងម៉ោងការងារឡើយ។